# ការជួបជុំស្ត្រីបង្គោលមកពីតាមមូលដ្ឋានជនបទ

សេដាកបានធ្វើការជំរុញ និងគាំទ្រក្រុមស្ត្រី និងក្រុមកសិករនៅតាមមូលដ្ឋានដែលតាមរយៈនោះ យើងសង្កេតឃើញថាចំនួនសមាជិកស្ត្រីមានច្រើន តែបើមើលទៅលើជួរអ្នកដឹកនាំវិញ គឺមានចំនួនតិច ឬ សឹងតែអត់មានតែម្តង។ តាមការពិតទៅគឺ ស្ត្រីមានចំនួនច្រើនហើយអាចធ្វើអ្វីបានជាច្រើនថែមទៀត ដូច្នេះហើយបានជានៅថ្ងៃនេះបណ្តាញកសិករ និងធម្មជាតិអញ្ជើញស្ត្រីជាជំហរនៅតាមភូមិមកជួបជុំគ្នា ជជែកគ្នាដើម្បីធ្វើការចែករំលែកបទពិសោធន៍គ្នាជុំវិញការងារអភិវឌ្ឍន៍ និងការឆ្លុះបញ្ចាំងលើភាពបម្រែបម្រួលរបស់ស្ត្រីចាប់តាំងពីសហការជាមួយអង្គការ សេដាក ឆ្លុះបញ្ចាំងតាមសហគមន៍ តើស្ត្រីមានភាពខ្លាំង និងខ្សោយអ្វីខ្លះ ចំណុចល្ងង់-ឆោតនៅកន្លែងណាខ្លះ? តើយើងធ្វើយ៉ាងម៉េចដើម្បីអាចជួយស្ត្រីទាំងនោះអោយមានការផ្លាស់ប្តូរមុខមាត់ និងជីវភាព? តើយើងត្រូវសហការគ្នារបៀបម៉េច ដើម្បីជួយស្ត្រីទាំងនោះអោយមានការផ្លាស់ប្តូរមុខមាត់ តើសេដាកគួរចូលរួមចំណែកជួយស្ត្រីទាំងនោះរបៀបណា?

ការជួបជុំនេះធ្វើឡើងក្នុងគោលបំណង:

- ជជែក និងដោះដូរបទពិសោធន៍ជុំវិញការងារអភិវឌ្ឍន៍
- វិភាគស្ថានភាពស្ត្រីតាមមូលដ្ឋាន
- យុទ្ធសាស្ត្រថា តើស្ត្រីគួរសហការគ្នាយ៉ាងណា ហើយថាសេដាកគួរជួយស្ត្រីជនបទយ៉ាងណា

ជាលទ្ធផល កិច្ចជួបជុំរយៈពេលពីរថ្ងៃ ថ្ងៃទី ២៣-២៤ ខែកក្កដា ឆ្នាំ ២០០៨ គឺជាឱកាសដ៏ល្អមួយសំរាប់អោយតំណាងក្រុមស្ត្រីជនបទ និងបុគ្គលិក សេដាក ក៏ដូចជាបុគ្គលិកពីអង្គការផ្សេងៗ និងមន្ទីរកិច្ចការនារីខេត្តដែលធ្វើការងារពាក់ពន្ធ័នឹងស្ត្រីជនបទ ធ្វើការចែករំលែក និងរៀនសូត្រពីគ្នា ពីស្ថានភាពបម្រែបម្រួលតំណាងក្រុមកសិករស្ត្រីតាមមូលដ្ឋានស្ថានភាព និងគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការគាំទ្រស្ត្រី និងការពិគ្រោះយោបល់លើ **កម្មវិធីរៀបចំបណ្តាញស្ត្រីជនបទថ្នាក់ជាតិ** ដែលជាឱកាសមួយដ៏សំខាន់ដើម្បីអោយមានតំណាងស្ត្រីសម្រាប់ធ្វើការងារបម្រើផលប្រយោជន៍ស្ត្រីពិតៗដូចជា ការការពារសិទ្ធ ការពារផលប្រយោជន៍ និងពាំនាំពាក្យសម្តី ព័ត៌មានពីថ្នាក់ក្រោមទៅកាន់ក្រសួងកិច្ចការនារី និងពីថ្នាក់ជាតិមកថ្នាក់មូលដ្ឋានវិញជាដើម ។ ជាទូទៅសម្រាប់រយៈពេល ២ ថ្ងៃនេះ យើងសម្រេចបានលទ្ធផលជាផ្លែផ្កាដូចការគ្រោងទុក។